LOWELL COMMUNITY CHARTER PUBLIC SCHOOL

206 Jackson Street Lowell, MA 01852 Phone (978) 323-0800 Fax (978) 323-4600 www.lccps.org

ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០

ជូនចំពោះ មាតាបិតាជាទីរាប់អាន,

សូមអរគុណដែលបានស្គាល់សាលារៀនសាធារណៈសហគមន៍ឆាទ័រនៃទីក្រុងឡូវែល (សាលារៀនឆាទ័រ) ។ សាលារៀនឆាទ័រជាសាលារៀនសាធារណៈមួយដែលកំពុងចុះឈ្មោះសិស្សថ្នាក់មត្តេយ្យបឋម១ ដល់ថ្នាក់ទី៨។ សាលារៀនឆាទ័រត្រូវបានបង្កើតឡើងក្រោមច្បាប់ឆាទ័ររបស់រដ្ឋ "Commonwealth Charter" ក្នុងខែកញ្ញាឆ្នាំ២០០០ ។ សាលារៀនឆាទ័រមិនរើសអើងដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ ជនជាតិដើម ជំនឿ ភេទ សំគាល់ភេទ ជនជាតិភាគតិច ទំនោរផ្លូវភេទ ពិការភាពផ្លូវចិត្ត ឬរាងកាយ ស្ថានភាពគ្មានផ្ទះសម្បែង អាយុវណ្ណៈ អត្តពលកម្ម តំរូវការពិសេស សមត្ថភាពជំនាញភាសាអង់គ្លេស ឬភាសាបរទេស ឬសមិទ្ធិផលសិក្សាមុនពេល។

សម្រាប់ឆ្នាំសិក្សា ២០២១-២០២២ យើងកំពុងទទួលយកពាក្យសិស្សសុំចូលរៀនចាប់ពីមត្តេយ្យបឋម១ ដល់ថ្នាក់ទី៨ ។ ពាក្យសុំនឹងត្រូវដាក់មកការិយាល័យសាលារៀនរបស់យើងជុតកំណត់ត្រឹម**ថ្ងៃពុធទី២៤ ខែកុម្ភៈឆ្នាំ ២០២១ វេលាម៉ោង ១២:០០ ថ្ងៃត្រង់។** ប្រសិនបើមានពាក្យសុំទទួលបានច្រើនជាងកន្លែងទំនេរដែលមាននៅក្នុងថ្នាក់រៀន ការចាប់ឆ្នោតនឹងត្រូវបានធ្វើឡើងសម្រាប់ថ្នាក់រៀននោះ **នៅថ្ងៃពុធទី៣ ខែមីនា ឆ្នាំ២០២១** ដើម្បីកំណត់ថា សិស្សណាមួយត្រូវបានគេផ្តល់ជូនកន្លែងថ្នាក់រៀន។ សូមពិនិត្យមើលគោលការណ៍ចុះឈ្មោះសម្រាប់ព័ត៌មានបន្ថែមដូចខាងក្រោម។**គោលការណ៍ពាក្យសិស្សសុំចូលរៀន:**

1. សិស្សដាក់ពាក្យសុំត្រូវតែជាសិស្សរស់នៅរដ្ឋម៉ាសាឈូសេត **ដើម្បីដាក់ពាក្យសុំចូលរៀន សុំចុះឈ្មោះរៀន និងចូលរៀន**នៅសាលារៀនឆាទ័រនៃរដ្ឋម៉ាសាឈូសេត។ សិស្សដាក់ពាក្យត្រូវផ្តល់ភស្តុតាងចំនួនពីរ(២)អំពីទីកន្លែងស្នាក់នៅលើកលែងតែសិស្សដែលគ្មានផ្ទះសម្បែងដែលត្រូវបានលើកលែងពីតម្រូវការទាំងនេះ។ (សូមពិនិត្យមើលគោលការណ៍ចុះឈ្មោះសម្រាប់បញ្ជីពេញលេញ)
2. កំរិតអាយុសំរាប់សិស្ស**ថ្នាក់មត្តេយ្យបឋម១ (KI)** មានអាយុ៤ឆ្នាំ គិតត្រឹមថ្ងៃទី១ ខែកញ្ញាសំរាប់ឆ្នាំចុះឈ្មោះចូលរៀន។
3. កំរិតអាយុសំរាប់សិស្ស**ថ្នាក់មត្តេយ្យបឋម២ (K2)** មានអាយុ៥ឆ្នាំ គិតត្រឹមថ្ងៃទី១ ខែកញ្ញាសំរាប់ឆ្នាំចុះឈ្មោះចូលរៀន។
4. សិទ្ធិទទួលបានសិស្សមត្តេយ្យបឋម១ (KI) និងមត្តេយ្យបឋម២ (K2) តម្រូវឲ្យមានសំបុត្រកំណើត ឬលិខិតបញ្ជាក់អាយុដែលចេញដោយរដ្ឋាភិបាលដូចជាលិខិតឆ្លងដែន ទំរង់លេខ I-94 ជាដើម។
5. សិស្សដាក់ពាក្យចាប់ពីថ្នាក់ទី១ ដល់ទី៨ ត្រូវបញ្ចប់ថ្នាក់សិក្សាដោយជោគជ័យមុនថ្នាក់ដែលពួកគេស្វែងរកដាក់ពាក្យសុំចូលរៀន។ សិទ្ធិទទួលបានរបស់សិស្សដាក់ពាក្យតម្រូវឱ្យមានរបាយការណ៍សិក្សា ឬសំបុត្របញ្ជាក់ពីសាលារៀន ឬសាលារៀនមណ្ឌលមុនដែលបង្ហាញពីការបញ្ចប់ការសិក្សាដោយជោគជ័យ។ ឯកសារចាំបាច់ទាំងអស់ត្រូវតែប្រគល់ឱ្យនៅត្រឹមថ្ងៃទី១៥ ខែសីហា។

មាតាបិតាត្រូវបានលើកទឹកចិត្តឱ្យសិក្សាឈ្វេងយល់អំពីសាលារៀនឆាទ័រមុនពេលដាក់ពាក្យសុំ។ សូមស្វែងរកមើលក្នុងគេហទំព័ររបស់យើងហើយចុះឈ្មោះមួយក្នុងវគ្គផ្សព្វផ្សាយព័ត៌មានបន្ថែមរបស់យើងជួបជាល់តាមប្រព័ន្ធអ៊ិនថឺណេតនៅថ្ងៃព្រហស្បតិ៍ទី១៤ ខែមករា ឆ្នាំ២០២១ នៅម៉ោង ៥:៣០ល្ងាច ឬ ថ្ងៃពុធទី៣ ខែកុម្ភៈ ឆ្នាំ២០២១ នៅម៉ោង៩:០០ព្រឹក។ ដោយសារតែជំងឺរាតត្បាតនៃកូវីដ-១៩ ដំណើរទេសចរណ៍សាលារៀនត្រូវបានផ្អាករហូតដល់មានសេចក្តីជូនដំណឹងបន្ថែមនៅពេលក្រោយ។

ដើម្បីដាក់ពាក្យសុំចូលរៀន:

1. ត្រូវបំពេញពាក្យសុំចូលរៀន (មួយសំរាប់សិស្សម្នាក់)។ ការបំពេញពាក្យសុំចូលរៀនតាមអ៊ីនថឺណេតនៅលើគេហទំព័ររបស់សាលារៀន www.lccps.org ឬ
2. ត្រូវនាំយកពាក្យសុំចូលរៀនដែលបានបំពេញត្រឹមត្រូវមកដាក់នៅសាលារៀន (ដោយសារជំងឺរាតត្បាតនៃកូវីដ-១៩ សូមដាក់ក្នុងប្រអប់សំបុត្រនៅខាងក្រៅអាគារសាលារៀន)។
3. ត្រូវផ្ញើពាក្យសុំចូលរៀនដែលបានបំពេញត្រឹមត្រូវទៅតាមអ៊ីមែល jwangutusi@lccps.org ឬ
4. ត្រូវផ្ញើពាក្យសុំចូលរៀនដែលបានបំពេញត្រឹមត្រូវទៅកាន់អាសយដ្ឋានខាងក្រោមនេះ:

Lowell Community Charter Public School
Attn: Admissions
206 Jackson Street
Lowell, MA 01852

ដោយសេចក្តីរាប់អានអំពីនាងខ្ញុំ,

P. Deborah Motew
Deputy Chief Operating Officer